00960723

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 07 / 11 / 2013
ម៉ោង (Time/Heure): 14:40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

002/19-09-2007-ECCC/TC
E1/234

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ សុក្រ ទី ២៥ ខែ តុលា ឆ្នាំ ២០១៣

## សវនាការលើអង្គសេចក្តី-សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល-ថ្ងៃ ២២១

**រៀបចំដោយ៖ ឌុច ផារី និង Miriam MAFESSANTI**

| កំណត់ហេតុអ្នកចូលរួម |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សាខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ឌុច ផារី, លោក ដាវ អានសាន, កញ្ញា Miriam MAFESSANTI |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោកស្រី ជា លាង, លោក Nicholas KOUMJIAN, លោក វេង ហ៊ត់, លោក William SMITH, លោក Tarik ABDULHAK, លោក Vincent de Wilde d'Estmael, លោក Keith REYNOR, លោក Dale LYSAK, |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួន), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Victor KOPPE |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN លោកស្រី Anta GUISSE |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Elisabeth SIMONNEAU- |

| |
|---|
| FORT, លោក ហុង គឹមសួន, លោក ឡោ ឈុនទី, លោកស្រី ម៉ុច សុវណ្ណារី, លោកស្រី Christine MARTINEAU, លោកស្រី Martine JACQUIN, លោកស្រី ជេត វណ្ណលី, លោកស្រី Lyma NGUYEN, លោកស្រី ទី ស្រីនណា, លោកមេធាវី ហុង គឹមសួន, លោកស្រីមេធាវី Beini YE |
| សាក្សី/ដើមបណ្ដឹង៖ គ្មាន |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ, លោកស្រី សួ សុធារី |
| ផ្សេងៗ៖ លោក Simon MEISENBERG |

| **<u>ពេលវេលាទូទៅរបស់តុលាការ៖</u>** | | |
|---|---|---|
| ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៣ | ចាប់ផ្ដើមម៉ោង៖ ០៩.០០ | បញ្ចប់ម៉ោង៖ ១៦.០៥ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.៣០ | បញ្ចប់ម៉ោង៖ ១០.៥០ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១២.០០ | បញ្ចប់ម៉ោង៖១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.០០ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៤ ម៉ោង ៥៥ នាទី |

**<u>កិច្ចដំណើរការនីតិវិធីផ្សេងទៀត</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| សេចក្ដីសន្និដ្ឋានទាក់ទងនឹងវិសាលភាពនៃការជំនុំជម្រះ (បញ្ហាទាក់ទងនឹងភស្ដុតាង) | លោក Arthur VERCKEN | ០៩.០៤<br>១០.៥៧ | ១០.៣១<br>១១.២៣ |
| សេចក្ដីសន្និដ្ឋានទាក់ទងនិងបរិបទប្រវត្តិសាស្ត្រមុនថ្ងៃទី១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងមូលហេតុនៃការជម្លៀសប្រជាជនពីភ្នំពេញ (ដំណាក់កាលទី១)<br><br>សេចក្ដីសន្និដ្ឋានទាក់ទងនឹងការជម្លៀសប្រជាជនដំណាក់កាលលើកទី២<br><br>សេចក្ដីសន្និដ្ឋានទាក់ទងនឹងការ | លោកស្រី Anta GUISSE | ១១.២៣<br>១៣.៣២<br><br>១៣.៤៣<br><br>១៣.៥៨ | ១២.០០<br>១៣.៤៣<br><br>១៣.៥៨<br><br>១៤.៣៩ |

| | | | |
|---|---|---|---|
| ទទួលខុសត្រូវរបស់ជនជាប់ចោទ | | | |
| សេចក្ដីសន្និដ្ឋានបញ្ចប់ទាក់ទងនឹងប្រវត្តនៃការអប់រំ ប្រវត្តនយោបាយ និងចរិកលក្ខណៈរបស់ជនជាប់ចោទ ខៀវ សំផន | មេធាវីអន្តរជាតិការពារក្ដី ខៀវ សំផន<br>មេធាវីជាតិការពារក្ដី ខៀវ សំផន | ០៩.០៤<br>១៥.០១ | ១៤.៣៨<br>១៦.០៣ |

**<u>សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>សេចក្ដីសន្និដ្ឋានទាក់ទងនឹង វិសាលភាពនៃការជំនុំជម្រះ (បញ្ហាទាក់ទងនឹងភស្តុតាង)</u>**

មេធាវីការពារក្ដី ខៀវ សំផន បានចាប់ផ្ដើមបង្ហាញនូវសេចក្ដីសន្និដ្ឋានបញ្ចប់នូវការពិភាក្សាដេញដោលរបស់ខ្លួន ។ ជាពិសេសលោក Arthur VERCKEN បានធ្វើសេចក្ដីសន្និដ្ឋានទាក់ទងនឹងវិសាលភាពនៃការជំនុំជម្រះ ដោយកត់សម្គាល់ថាព្រះរាជអាជ្ញាបានលើកឡើងពីដីកាដំណោះស្រាយទាំងមូល ជាជាងវិសាលភាពនៃដីកាដំណោះស្រាយដែលត្រូវបានកម្រិតក្នុងដីកាបំបែកសំណុំរឿង ។ លោក Arthur VERCKEN ក៏បានលើកឡើងផងដែរថា មានបញ្ហាមួយចំនួនទាក់ទងនឹងយថាភាពនៃភស្តុតាងឯកសារដែលមានក្នុងសំណុំរឿង ។

លោកស្រី Anta GUISSE បានធ្វើសេចក្ដីសន្និដ្ឋានទាក់ទងនឹងបរិបទប្រវត្តិសាស្ត្រមុនពេលខ្មែរក្រហមឡើងកាន់អំណាច និងមូលហេតុនៃការជម្លៀសប្រជាជនដំណាក់កាលទីមួយ និងការជម្លៀសប្រជាជនដំណាក់កាលទីពីរ ។

លោក គង់ សំអុន បានធ្វើសេចក្ដីសន្និដ្ឋានទាក់ទងនឹងប្រវត្តិនៃការអប់រំ ប្រវត្តិនយោបាយ និងចរិកលក្ខណៈរបស់លោក ខៀវ សំផន ។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>**

| លេខ E3 | លេខកសចស | ចំណងជើង | ចំណាត់ថ្នាក់ | ERN ខ្មែរ | ERN អង់គ្លេស | ERN បារាំង |
|---|---|---|---|---|---|---|

**<u>ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖</u>**

- ប្រធានអង្គជំនុំជម្រះបានធ្វើការប្រមានដល់លោក Arthur VERCKEN ចំនួនពីរដងឲ្យគោរពទៅតាមក្រមសីលធម៌របស់មេធាវី និងកម្រិតការធ្វើសេចក្ដីសន្និដ្ឋានរបស់ខ្លួនត្រឹមអង្គហេតុដែលពាក់ព័ន្ធ ។

- អង្គជំនុំជម្រះបានប្រកាសថា ការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន នឹងបន្តនៅថ្ងៃចន្ទ ទី ២៨ ខែ តុលា ឆ្នាំ ២០១៣ ។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅមន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួន នួន ជា មកបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ និងលោក ខៀវ សំផន មកសាលសវនាការវិញនៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៣ ឱ្យបានមុនម៉ោង ០៩ ព្រឹក ។

| <u>កាលវេលាសវនាការបន្ត</u> |
|---|
| សវនាការនឹងបន្តទៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៣ ចាប់ផ្តើមពីម៉ោង ៩.00 ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៣

ក្រឡាបញ្ជី ក្រឡាបញ្ជី

ឌុច ផារ៉ា Miriam MAFESSANTI